# ស្វែងយល់អំពីដំណើរការធានាសញ្ញាបណ្ណរបស់ CGCC

ដោយ៖ លោក ជ័យ វីរៈ ប្រធានការិយាល័យអភិវឌ្ឍន៍អាជីវកម្ម (ការធានាលើសញ្ញាបណ្ណ)
លោក សុធា ច័ន្ទសិរីវុឌ្ឍ អនុប្រធានការិយាល័យអភិវឌ្ឍន៍អាជីវកម្ម (ការធានាលើសញ្ញាបណ្ណ)

## ដំណើរការនៃការធានាសញ្ញាបណ្ណរបស់សាជីវកម្មធានាឥណទានកម្ពុជា (CGCC)៖ ជំហានសាមញ្ញសម្រាប់អ្នកបោះផ្សាយ

KH ការបោះផ្សាយសញ្ញាបណ្ណស្តាប់ទៅហាក់ដូចជាស្មុគស្មាញ ប៉ុន្តែជាមួយការគាំទ្រពីសាជីវកម្មធានាឥណទានកម្ពុជា (CGCC) ដំណើរការត្រូវបានរៀបចំឡើងយ៉ាងល្អ និងងាយស្រួលខុសពីការគិតរបស់អ្នក។ ការធានាសញ្ញាបណ្ណរបស់ CGCC ជួយបង្កើនទំនុកចិត្តរបស់វិនិយោគិន បង្កើនកម្រិតឥណទានរបស់អ្នក និងទទួលបានដើមទុនជាមួយលក្ខខណ្ឌល្អប្រសើរជាងមុន។

ដំណើរការដាក់ពាក្យស្នើសុំ ត្រូវបានរៀបចំឡើងដើម្បីណែនាំដល់ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណតាមដំណាក់កាលនីមួយៗ ចាប់ពីការបង្ហាញចំណាប់អារម្មណ៍ដំបូង រហូតដល់ការធានាផ្លូវការ។ ដំណាក់កាលនីមួយៗមានតម្លាភាព ដោយ CGCC ធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណ ដើម្បីធានាថាពួកគេបានត្រៀមខ្លួនរួចជាស្រេច។

### ដំណើរការនៃការស្នើសុំការធានាសញ្ញាបណ្ណ




### ជំហានទី ១៖ លិខិតបញ្ជាក់ចំណាប់អារម្មណ៍

ដំណើរការទាំងមូលចាប់ផ្តើមដោយ លិខិតបញ្ជាក់ចំណាប់អារម្មណ៍ដ៏សាមញ្ញមួយ។ តាមរយៈការចែករំលែកនូវ ព័ត៌មានលម្អិតជាមូលដ្ឋានរបស់ក្រុមហ៊ុន របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរយៈពេល ៣ឆ្នាំចុងក្រោយ ព័ត៌មានអំពីសញ្ញាបណ្ណ បញ្ជីឈ្មោះវិនិយោគិនសក្តានុពល ព័ត៌មានអភិបាលកិច្ចសាជីវកម្ម និងកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនធានាទិញមូលបត្រ។ CGCC នឹងពិនិត្យលើលក្ខខណ្ឌដំបូង។ ដំណាក់កាលនេះមានភាពរហ័ស និងមិនស្មុគស្មាញ។

### ជំហានទី ២៖ ការដាក់ពាក្យស្នើសុំជាផ្លូវការ

បន្ទាប់ពីការត្រួតពិនិត្យលើលក្ខខណ្ឌដំបូងបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណត្រូវបានអញ្ជើញឱ្យដាក់ពាក្យស្នើសុំធានាសញ្ញាបណ្ណជាផ្លូវការ។ ឯកសារតម្រូវរួមមាន ទម្រង់ពាក្យស្នើសុំធានាសញ្ញាបណ្ណរបស់ CGCC ផែនការអាជីវកម្ម ផែនការថវិកាលម្អិតដែលភ្ជាប់ជាមួយការព្យាករណ៍លំហូរសាច់ប្រាក់ ឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុន ចំណាត់ថ្នាក់ឥណទាន អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតបទប្បញ្ញត្តិពាក់ព័ន្ធទាំងអស់។ បន្ថែមពីនេះ ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណត្រូវរំពឹងថា នឹងផ្តល់នូវរបាយការណ៍ត្រួតពិនិត្យបំពេញកាតព្វកិច្ចតាមច្បាប់ ផ្នែកគតិយុត្ត ផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការ និងរបាយការណ៍ផលប៉ះពាល់សង្គមនិងបរិស្ថាន។ ឯកសារធានា កិច្ចសន្យាសំខាន់ៗជាមួយភាគីពាក់ព័ន្ធ និងឯកសារផ្សេងទៀតអាចត្រូវបានស្នើសុំបន្ថែមតាមការចាំបាច់។

### ជំហានទី ៣៖ ការសិក្សាវាយតម្លៃ

ក្នុងដំណាក់កាលវាយតម្លៃ ដែលជាការវាយតម្លៃតាមឯកសារដែលបានផ្តល់ឱ្យ CGCC ត្រួតពិនិត្យលើពាក្យស្នើសុំធានាសញ្ញាបណ្ណ ដើម្បីវាយតម្លៃភាពរឹងមាំផ្នែកហិរញ្ញវត្ថុ កម្រិតនៃឥណទាន និងលទ្ធភាពសម្រេចបាននៃគម្រោងរបស់ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណ។ ការវាយតម្លៃនេះរួមបញ្ចូលទាំងការវិភាគលើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ការព្យាករណ៍លំហូរសាច់ប្រាក់ អភិបាលកិច្ចសាជីវកម្ម និងហានិភ័យសំខាន់ៗដើម្បីធានាថាសញ្ញាបណ្ណនោះបំពេញតាមលក្ខខណ្ឌនិងសូចនាករហានិភ័យរបស់ CGCC មុនពេលបន្តទៅដំណាក់កាលចុះត្រួតពិនិត្យបំពេញកាតព្វកិច្ចតាមច្បាប់។

### ជំហានទី ៤៖ ការអនុម័តជាគោលការណ៍

បន្ទាប់ពីការវាយតម្លៃលើឯកសាររួចមក CGCC អាចចេញ លិខិតអនុម័តជាគោលការណ៍ ដែលបង្ហាញពីការអនុម័តបឋមដើម្បីបន្តនីតិវិធីបន្ទាប់។ លិខិតអនុម័តជាគោលការណ៍បញ្ជាក់ថា ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណបានបំពេញតាមលក្ខខណ្ឌ និងសូចនាករហានិភ័យដំបូង ហើយនឹងកំណត់លក្ខខណ្ឌសម្រាប់ដំណាក់កាលបន្តនៃការចុះត្រួតពិនិត្យបំពេញកាតព្វកិច្ចតាមច្បាប់ មុននឹងឈានដល់ការអនុម័តចុងក្រោយ។

### ជំហានទី ៥៖ ការចុះត្រួតពិនិត្យបំពេញកាតព្វកិច្ចតាមច្បាប់

បន្ទាប់ពីទទួលបានលិខិតអនុម័តជាគោលការណ៍ CGCC នឹងធ្វើការចុះត្រួតពិនិត្យបំពេញកាតព្វកិច្ចតាមច្បាប់លម្អិត ដែលគ្របដណ្តប់លើផ្នែកហិរញ្ញវត្ថុ ផ្លូវច្បាប់ ប្រតិបត្តិការ ផលប៉ះពាល់បរិស្ថាននិងសង្គម របស់ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណ។ ដំណើរការនេះរួមមាន៖ ការចុះពិនិត្យទីតាំង ការសម្ភាសន៍ថ្នាក់ដឹកនាំ និងការផ្ទៀងផ្ទាត់ឯកសារ និងរបាយការណ៍សំខាន់ៗ ដូចជារបាយការណ៍នៃការចុះត្រួតពិនិត្យបំពេញកាតព្វកិច្ចតាមច្បាប់ដោយយកចិត្តទុកដាក់ផ្នែកហិរញ្ញវត្ថុ និងច្បាប់ជាដើម។ គោលបំណងគឺដើម្បីបញ្ជាក់នូវភាពគួរឱ្យទុកចិត្តជារួម ភាពរឹងមាំនៃអភិបាលកិច្ចសាជីវកម្ម និងសមត្ថភាពរបស់ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណ មុននឹងឈានទៅដល់ការអនុម័តចុងក្រោយ។

### ជំហានទី ៦៖ ការអនុម័តជាផ្លូវការ និងការចេញលិខិតធានា

បន្ទាប់ពីបញ្ចប់ការចុះត្រួតពិនិត្យបំពេញកាតព្វកិច្ចតាមច្បាប់ទាំងស្រុង និងឈានទៅដល់ដំណាក់កាលអនុម័តជាផ្លូវការ ដែលជាជំហានចុងក្រោយមុនការធានា។ នៅដំណាក់កាលនេះ ការវាយតម្លៃ និងលក្ខខណ្ឌទាំងអស់ត្រូវបានព្រមព្រៀងទាំងអស់គ្នា មុននឹងឈានដល់ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងធានា និងការចុះអនុវត្តការធានាសញ្ញាបណ្ណជាផ្លូវការ។

## អនុសាសន៍សម្រាប់ក្រុមហ៊ុនដែលចង់បោះផ្សាយសញ្ញាបណ្ណ

ក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយសញ្ញាបណ្ណត្រូវបានលើកទឹកចិត្តឱ្យចាប់ផ្តើមរៀបចំឯកសារសំខាន់ៗឱ្យបានឆាប់ជាមុនដូចជា របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ការព្យាករណ៍អាជីវកម្ម របាយការណ៍ចុះត្រួតពិនិត្យបំពេញកាតព្វកិច្ចតាមច្បាប់ និងជាពិសេសការធ្វើចំណាត់ថ្នាក់ឥណទាន។ ការរៀបចំជាមុនអាចជួយសម្រួលដល់ការវាយតម្លៃ ដែលនាំឱ្យការអនុម័តមានភាពរលូន និងលឿនជាងមុន។

## តើអ្នកបានត្រៀមខ្លួនចាប់ផ្តើមដំណើរការធានាសញ្ញាបណ្ណហើយឬនៅ?

ជាមួយនឹងការជួយគាំទ្ររបស់ CGCC ដំណើរការធានាសញ្ញាបណ្ណ មិនត្រឹមតែអាចគ្រប់គ្រងបានល្អប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាជំហានដ៏មានតម្លៃ ឆ្ពោះទៅរកភាពជោគជ័យនៅក្នុងទីផ្សារផងដែរ។ ក្រុមការងាររបស់យើងត្រៀមខ្លួនជាស្រេចដើម្បីជួយណែនាំអ្នកចាប់ពីការសាកសួរព័ត៌មានដំបូង រហូតដល់ការធានាជាផ្លូវការ។

ដើម្បីស្វែងយល់បន្ថែមអំពីការធានាសញ្ញាបណ្ណរបស់ CGCC ដែលគាំទ្រដល់ការបោះផ្សាយសញ្ញាបណ្ណ របស់អ្នក សូមទាក់ទងមកកាន់ក្រុមការងាររបស់យើងសម្រាប់ព័ត៌មានបន្ថែមតាមរយៈអ៊ីមែល និងលេខទូរសព្ទដូចខាងក្រោម៖

bondguarantee@cgcc.com.kh
០២៣ ៧២២ ១២៣
www.cgcc.com.kh/bond-guarantee

---

# Understanding CGCC Bond Guarantee Process

By : Mr. Chey Virek, Manager of Business Development (Bond Guarantee)

Mr. Sothea Chansereyvuth, Deputy Manager of Business Development (Bond Guarantee)

## CGCC Bond Guarantee Process: Simple Steps for Issuers

EN Issuing a bond may sound complex, but with the support of the Credit Guarantee Corporation of Cambodia (CGCC), the process is well structured, and more convenient than many expect. CGCC's bond guarantee helps issuers strengthen investor confidence, enhance their credit profile, and access capital on better terms.

The application journey has been designed to guide issuers step by step — from the expression of interest to the official guarantee. Each stage is transparent, where CGCC works closely alongside with issuers to ensure they are well prepared.

### CGCC's Bond Guarantee Application Process




### Step 1: Letter of Intent

It all begins with a simple Letter of Intent (LOI). By sharing basic company details, historical financial statements, bond issuing information, list of potential investors, corporate governance information and engagement letter with underwriter, issuers open the door for CGCC to check initial eligibility. This step is quick and straightforward.

### Step 2: Full Application

Once the preliminary eligibility check is completed, issuers are invited to submit a full guarantee application. This typically includes the CGCC Bond Guarantee Application Form, a detailed business or budget plan with cash flow projections, constitutional and corporate approval documents, credit rating, and all relevant regulatory licenses and permits. In addition, issuers are expected to provide commercial and legal due diligence reports covering financial, operational, legal, social and environmental aspects. Security documents, key contracts with related parties, and any other supporting materials may also be required where necessary.

### Step 3: Assessment

At the Assessment Stage (Desk Assessment), CGCC reviews the bond application to evaluate the issuer's financial soundness, creditworthiness, and project viability. This includes analysis of audited financial statements, cash flow projections, governance, and key risks to ensure the bond meets CGCC's eligibility and risk criteria before moving to due diligence stage.

### Step 4: Approval in Principle (AIP)

After the desk assessment, CGCC may issue an Approval in Principle (AIP) indicating preliminary approval to proceed. The AIP confirms the issuer meets initial eligibility and risk criteria and sets conditions for the next stage of due diligence before final approval.

### Step 5: Due Diligence

After receiving Approval in Principle (AIP), CGCC conducts a comprehensive due diligence process covering financial, legal, operational, environmental and social impact aspects of the issuer. This includes site visits, management interviews, and verification of key documents and reports, such as financial and legal due diligence findings, to confirm the issuer's overall credibility, governance, and capacity before final approval.

### Step 6: Effective Approval & Guarantee Issuance

After completing due diligence, the process advances to the Effective Approval stage or the final step before finalizing the guarantee. At this stage, all assessments, terms and conditions are confirmed to be satisfactory prior to the issuance of the Guarantee Agreement and the formal execution of the bond guarantee.

### Recommendations to Potential Issuers

Potential bond issuers are encouraged to engage early in the process and prepare key documents such as audited financial statements, business projection, due diligence report and especially credit ratings in advance. Early preparation helps streamline the assessment which leads to smoother and faster approval.

### Ready to Start Your Bond Guarantee Journey?

With CGCC's support, the bond guarantee process is not only manageable but also a valuable step toward market success. Our team is here to guide you from the very first inquiry to the final guarantee.

To explore how CGCC's bond guarantee can support your bond issuance, we encourage you to reach out to our team for more information.